# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៥ សសរ

## សេចក្ដីសំរេច
## ស្ដីពី
## ការបង្កើតក្រុមការងារ
## សំរាប់សិក្សាគំរោងប្លង់សាងសង់អាគារទីស្ដីការគណៈរដ្ឋមន្ត្រីថ្មី

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្ដីពី ការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់

### សម្រេច

**ប្រការ១ .-**

បង្កើតក្រុមការងារ សំរាប់សិក្សាគំរោងប្លង់សាងសង់អាគារទីស្ដីការគណៈរដ្ឋមន្ត្រីថ្មី ដែលមានសមាសភាពដូចខាងក្រោម÷

១. ឯកឧត្ដម **យឹម ឆៃលី** ទីប្រឹក្សារាជរដ្ឋាភិបាល ប្រធាន

២. ឯកឧត្តម **ទី យ៉ាវ** អនុប្រធាន ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ សមាជិក

៣. ឯកឧត្តម **ម៉ម សុផាន់ណា** អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ សមាជិក

៤. ឯកឧត្តម បណ្ឌិតរដ្ឋ **តឹម សំណាង** អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សមាជិក

៥. ឯកឧត្តម **អ៊ឹក សុមេត្ត** អគ្គនាយករង អាជ្ញាធរអប្សរា សមាជិក

៦. លោក **ហ៊ុយ ណារ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ សមាជិក

**ប្រការ២ .-**

ក្រុមការងារមានភារកិច្ចទំនាក់ទំនងការងារ និងការសិក្សាគំរោងប្លង់សាងសង់អាគារទីស្តីការគណៈរដ្ឋមន្ត្រីថ្មី ជាមួយភាគីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីលើកជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសាម៉ីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ